# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## រោងចក្រកាត់ដេរ វ៉ាយ ធី ស៊ី ឧបប៉ូរ៉េសិន

អាស័យដ្ឋាន: ភូមិវល្លិសរ ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

## កិច្ចព្រមព្រៀងរួម
## ស្តីពី
## ការព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងនេះត្រូវបានរៀបចំធ្វើឡើងរវាងរោងចក្រ វ៉ាយ ធី ស៊ី ឧបប៉ូរ៉េសិន ដែលកំណត់ជាភាគី(ក) និង តំណាងកម្មករ សហជីព រោងចក្រ វ៉ាយ ធី ស៊ី ឧបប៉ូរ៉េសិន ដែលកំណត់ជាភាគី (ខ)។

**ភាគីទាំងពីរបានព្រមព្រៀង និងឯកភាពគ្នាតាមប្រការ និងលក្ខ័ណ្ឌដូចខាងក្រោម៖**

ប្រការ ១៖ ក្រុមហ៊ុនស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករ២៥៣២នាក់(ស្រី១៦៣១នាក់)រយៈពេល ១០ថ្ងៃ ចាប់ពីថ្ងៃទី ១៨ ខែមីនា២០២១ ដល់ថ្ងៃ ២៧ ខែមីនា២០២១ ក្នុងចំនោមកម្មករសរុប ២៧១៨នាក់(ស្រី១៧៦០នាក់)។

ប្រការ ២៖ ក្រុមហ៊ុនសម្រេចផ្តល់ជូនប្រាក់ឧបត្ថមចំនួន១០ដុល្លារអាមេរិកសម្រាប់កម្មករនិយោជិតម្នាក់ៗក្នុងការព្យួរ១០ថ្ងៃតាមប្រកាសរបស់ក្រសួងការងារនឹងបណ្តុះបណ្តាលវជ្ជាជីវះលេខ០៤៥/២០ ក.ប/ស.ណ.ន.ខ.លចុះកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ក្នុងនោះ :

- ចំនួន១០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យារការងាររយៈពេល៧ថ្ងៃដល់១០ថ្ងៃ។
- ចំនួន២០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យារការងាររយៈពេល១១ថ្ងៃដល់២០ថ្ងៃ។
- ចំនួន៣០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យារការងាររយៈពេល២១ថ្ងៃដល់១ខែ។

ទទួលបានប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលតាមរយៈភ្នាក់ងាររឹងដូចខាងក្រោម:

- ចំនួន១៥ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យារការងាររយៈពេល៧ថ្ងៃដល់១០ថ្ងៃ។
- ចំនួន៣០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យារការងាររយៈពេល១១ថ្ងៃដល់២០ថ្ងៃ។
- ចំនួន៤០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យារការងាររយៈពេល២១ថ្ងៃដល់១ខែ។

ប្រការ ៣ កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់មានការកែប្រែសារជាថ្មី។

ភាគីទាំងពីរបានឯកភាពនិងផ្តិតស្នាមមេដៃទុកជាសាក្សី

ថ្ងៃអង្គារ ១៣ រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ពស២៥៦៤
ធ្វើនៅកំពង់ស្ពឺ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២១

ភាគី (ក) នាយកគ្រប់គ្រងរោងចក្រ

ព្រះរាជាណាចក្រកម្ពុជា
វ៉ាយ ធី ស៊ី ខបប៉ូរេសិន
YTC CORPORATION
ADMINISTRATIVE
ផ្នែករដ្ឋបាល ខេត្តកំពង់ស្ពឺ

លោក Song Nak Hto

ភាគី(ខ) តំណាងកម្មករ រោងចក្រ

ផាត់ សាម៉េត
ញៀន ឡាប
ស្វាយ ស៊ី
ម៉ៃ សាមិត
ម៉ៅ ពិសី
ខាត់ ស៊ុនរី
ឡៅ ស្រីនោ
ប៊ុន ភារុន
ប៊ី សិរីវ័ត្ន
រឿន សារី
ឆេង ឡី
ឈៀក ស៊ីវលាង
ឆែម វណ្ណៈ
យ៉ា ស្រីហ៊ុយ
អ៊ុន ឡឿន